ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយអំពីសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា

ខេត្តសៀមរាប ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥

សូមគោរព ៖

- ឯកឧត្តម ងី ចន្ទ្រផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- ឯកឧត្តម ប៊ុនថាឬទ្ធិ អភិបាលរងខេត្តសៀមរាប
- ឯកឧត្តម កុយ សង សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប
- លោក លោកស្រី នាងកញ្ញា តំណាងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ថ្នាក់ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអនេក ដែលបានមកជួប ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ក្នុងសិក្ខាសាលាដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា ដើម្បីផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា នៅខេត្តសៀមរាប នាពេលនេះ ។ ពិធីនេះ ត្រូវបានរៀបចំឡើងតាមស្មារតីណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបន្ទាប់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីថ្លែងការណ៍រួម កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ដើម្បីផ្សព្វផ្សាយ និងជម្រាបជូនសាធារណជន ជាពិសេស អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងមូលដ្ឋាន និងគ្រឹះស្ថានហិរញ្ញវត្ថុ ឱ្យបានដឹងច្បាស់ថា បច្ចុប្បន្ន មានអង្គការមិនមែនរដ្ឋាភិបាល សមាគមសប្បុរសធម៌ ឬជាសប្បុរសជនមួយចំនួន ដែលបានធ្វើការឱ្យខ្ចីប្រាក់តាមជនបទនិងទីប្រជុំជន ហើយតែងតែចាត់ខ្លួនឯងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

ទន្ទឹមពេលនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមអភិបាលខេត្តសៀមរាប និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ បានបង្កបរិយាកាសល្អ និងជួយសម្រួលដល់កិច្ចដំណើរការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ នៅក្នុងរដ្ឋបាលខេត្ត ។ កិច្ចសហការនេះ គឺជាផ្នែកមួយយ៉ាងសំខាន់និងចាំបាច់បំផុត ហើយពិតជាបានរួមចំណែកអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ឱ្យមានការរីកចម្រើនស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែង និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានមជ្ឈដ្ឋានជាតិ-អន្តរជាតិ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកថាជាវិស័យគន្លឹះ ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងគាំទ្រកំណើនសេដ្ឋកិច្ច ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនអង្គសិក្ខាសាលា ពីប្រវត្តិនៃការអភិវឌ្ឍរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាដូចតទៅ ៖

**១/. ប្រវត្តិនៃការខ្ចីឥណទាន និងការផ្តល់ឥណទានរបស់ខ្មែរយើង**

ការខ្ចីបុល គឺជាសកម្មភាពមួយដែលកើតមានឡើងតាំងពីបុរាណកាល តាំងពីយូរយារណាស់មកហើយ ក្នុងគ្រប់សង្គមមនុស្ស ។ ការខ្ចីបុល កើតមានតាំងពីសង្គមមនុស្សចេះផលិតដើម្បីជួញដូរ ។ នៅក្នុងសង្គមមនុស្ស តែងតែមានមនុស្ស ដែលសល់លុយជាបណ្តោះអាសន្ន និងអ្នកដែលខ្វះលុយជាបណ្តោះអាសន្ន ដោយសារមូលហេតុផ្សេងៗ ។ នៅពេលនោះហើយ ដែលមានតម្រូវការក្នុងការខ្ចីបុលដើម្បីយកមកប្រើប្រាស់។

ការខ្ចីបុលមានមុខសកម្មផង និងអសកម្មផង ។ ប្រព័ន្ធខ្ចីបុលដែលមានតាំងពីបុរាណមកដែលគ្មានការគ្រប់គ្រងនិងដែលកើតឡើងឯកឯងដែលយើងហៅថា "**ការខ្ចីបុលពីឈ្មួញ ឬខ្ចីបុលក្រៅផ្លូវការ**" ត្រូវបានគេទទួលស្គាល់ថាជាមូលហេតុធ្វើឱ្យមានការកេងប្រវ័ញ្ច ។

នៅក្នុងសង្គមខ្មែរយើងពីបុរាណ ធ្លាប់មានពាក្យគេនិយាយថា "**ការរដូវវស្សា ១ កន្តាំង ដល់រដូវប្រាំង ១ តៅ**" ។ នៅប្រទេសខ្មែរ ក៏ដូចជានៅប្រទេសជាច្រើនលើសកលលោករដ្ឋាភិបាលគ្រប់របបតែងតែព្យាយាមចង់គ្រប់គ្រងប្រព័ន្ធខ្ចីបុលនេះ ដើម្បីជៀសវាងកុំឱ្យមានការកេងប្រវ័ញ្ចហួសហេតុ ហើយផ្តល់ជាផលវិជ្ជមានឱ្យបានច្រើនដល់អ្នកខ្ចីបុលឱ្យបានកាន់តែច្រើន ។ កាលនៅសម័យសង្គមរាស្ត្រនិយម រដ្ឋាភិបាលព្យាយាមបង្កើតប្រព័ន្ធឥណទានជនបទ តាមរយៈការបង្កើត "**រាជមន្ទីរសហករណ៍យើង**" ការបង្កើតសហករណ៍ផ្តល់ទុន និងការបង្កើតសហករណ៍ឧបភោគបរិភោគជាដើម ។ល។ នេះជាប្រព័ន្ធដែលគ្រប់គ្រងដោយរដ្ឋ ។ រដ្ឋបានលូកដៃចូលជ្រៅទៅធ្វើអន្តរាគមន៍ ទៅក្នុងការគ្រប់គ្រង ។ ក្រោយពីដំណើរការមួយរយៈ ប្រព័ន្ធនេះដើរទៅមិនរួច ហើយទីបំផុតក៏បរាជ័យ មិនអាចដំណើរការធ្វើហិរញ្ញប្បទានជនបទបាន ។

នៅឆ្នាំ១៩៨០ ប្រព័ន្ធធនាគារថ្មីមួយត្រូវបង្កើតឡើង ជាប្រព័ន្ធធនាគារមួយថ្នាក់ ។ ប្រព័ន្ធឥណទានទាំងមូលត្រូវបានគ្រប់គ្រងដោយរដ្ឋ ។ បរិមាណទុននិងអត្រាការប្រាក់ត្រូវបានកំណត់ដោយរដ្ឋ ដើម្បីជៀសវាងពីការកេងប្រវ័ញ្ចពីអ្នកខ្ចី ។ នៅទីបំផុត ប្រព័ន្ធ

នេះក៏ដំណើរការដោយមិនមានប្រសិទ្ធភាព តម្លាភាព និងសមធម៌ ។ អ្នកខ្ចីបានចេះតែបាន អ្នកមិនបានខ្ចីនៅតែមិនបានខ្ចី ទីបំផុត អ្នកខ្ចីកេងប្រវ័ញ្ចពីរដ្ឋទៅវិញ ។ បំណុលជាច្រើនក្លាយជាបំណុលអាក្រក់ ទារវិញមិនបាន ដែលធ្វើឱ្យរដ្ឋបាត់បង់ទុនយ៉ាងច្រើន ។

នៅទសវត្សរ៍ឆ្នាំ១៩៩០ ប្រព័ន្ធឥណទានជនបទថ្មីមួយបានកើតឡើង ក្នុងរូបភាពជាអង្គការមិនមែនរដ្ឋាភិបាល និងមានលក្ខណៈជាប្រព័ន្ធឯកជន ទទួលបានទុនពីក្រៅប្រទេសយកមកដំណើរការជាដំបូង ក្រោមរូបភាពមនុស្សធម៌ ។ ក្រោយមកបន្តិចម្តងៗ បានដំណើរការជាប្រព័ន្ធរកស៊ីមានចំណេញខាតទាំងស្រុង ។

នៅចុងទសវត្សរ៍ឆ្នាំ១៩៩០ "គណៈកម្មាធិការឥណទានសម្រាប់អភិវឌ្ឍន៍ជនបទ" រួមជាមួយធនាគារជាតិនៃកម្ពុជា បានព្យាយាមគ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាលទាំងនោះ ដោយតម្រូវឱ្យអង្គការក្រៅរដ្ឋាភិបាលទាំងនោះចុះបញ្ជី និងទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដោយត្រូវគោរពតាមវិធានធ្វើប្រតិបត្តិការ និងវិធានការប្រុងប្រយ័ត្ន ហើយខ្លះអាចទទួលប្រាក់បញ្ញើពីអតិថិជនថែមទៀត ។ ប្រព័ន្ធនេះឈរលើគោលការណ៍ទីផ្សារ និងការប្រកួតប្រជែង ប៉ុន្តែមានការគ្រប់គ្រងដោយរដ្ឋដែលដើរតួនាទីជាបញ្ញត្តិករ ។

## ២/. ការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ចាប់ពីទសវត្សរ៍ឆ្នាំ១៩៨០ មក

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ត្រូវបានកកើតឡើងចាប់ពីទសវត្សឆ្នាំ១៩៨០ ហើយបានវិវត្តខ្លាំងនាដើមទសវត្សឆ្នាំ១៩៩០ ។ វិស័យមីក្រូហិរញ្ញវត្ថុត្រូវបានអភិវឌ្ឍដោយដំបូងចាប់ផ្តើមចេញពីរូបភាពជាអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការទទួលជំនួយមជ្ឍដ្ឋានជាតិនិងអន្តរជាតិ ដើម្បីបម្រើសកម្មភាពមនុស្សធម៌ ដោយធ្វើសកម្មភាពផ្តល់ប្រាក់កម្ចីខ្នាតតូចដល់ប្រជាជននៅតាមតំបន់ជនបទ ក្នុងគោលបំណងផ្តល់ឱ្យប្រជាជនទាំងនោះនូវដើមទុនសម្រាប់ការបង្កើតនិងការបង្កើនមុខរបរអាជីវកម្មរបស់ខ្លួន ។ នៅដំណាក់កាលនេះ សកម្មភាពនៃការផ្តល់ឥណទានរបស់អង្គការក្រៅរដ្ឋាភិបាលពុំទាន់ស្ថិតក្រោមបទប្បញ្ញត្តិ និងការត្រួតពិនិត្យដោយប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជានៅឡើយទេ ។

ជាមួយនឹងចំណាប់អារម្មណ៍ក្នុងការពង្រីកសេវាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពសម្រាប់ប្រជាពលរដ្ឋ និងដោយយល់ឃើញថា លទ្ធភាពផ្តល់ជំនួយសម្រាប់គម្រោងមីក្រូឥណទានកាន់តែថមថយទៅៗ ការកម្លាយខ្លួនពីអង្គការមិនមែនរដ្ឋាភិបាល ទៅជាស្ថាប័នស្វែងរកប្រាក់ចំណេញគឺជាការចាំបាច់ ក្នុងន័យថា ស្ថាប័នអាចមានលទ្ធភាពធ្វើប្រតិបត្តិការផ្តល់ឥណទានប្រកបដោយឯករាជ្យភាពនិងនិរន្តរភាព ដោយមិនពឹងផ្អែកលើប្រភពជំនួយដែលមានលក្ខណៈមិនស្ថិតស្ថេរនោះទៀតទេ ។

ដោយយល់ឃើញពីភាពចាំបាច់នេះ អ្នកគាំទ្រវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានចាប់ផ្តើមប្រជុំពិភាក្សាជាបន្តបន្ទាប់ ដើម្បីផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ឱ្យស្របតាមគោលដៅ និងកំណត់បាននូវចក្ខុវិស័យរួម សម្រាប់ការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ព្រមទាំងបានបង្កើតវេទិកាពិភាក្សាជាបន្តបន្ទាប់ ដើម្បីកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុជនបទ ស្របពេលដែលគណៈកម្មាធិការឥណទានសម្រាប់អភិវឌ្ឍន៍ជនបទ (គជទាន) ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ក្នុងការផ្តល់ជាកម្មវិធីនយោបាយ និងកិច្ចពិភាក្សាឱ្យកាន់តែទូលំទូលាយដើម្បីអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុ ។

ស្របនិងការវិវឌ្ឍនេះ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលស្របតាមសេដ្ឋកិច្ចទីផ្សារ ត្រូវបានអនុម័តនៅឆ្នាំ១៩៩៦ ជាក្របខណ្ឌច្បាប់ដំបូងសម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តតួនាទីជាអាជ្ញាធររូបិយវត្ថុនិងអាជ្ញាធរត្រួតពិនិត្យ ។ ទន្ទឹមនេះ ច្បាប់ស្តីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលត្រូវបានអនុម័តនៅឆ្នាំ១៩៩៩ បានបង្កើតឡើងនូវក្របខណ្ឌច្បាប់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាហិរញ្ញវត្ថុ ហើយបានផ្តល់អំណាចដល់ធនាគារជាតិនៃកម្ពុជាក្នុងការចេញបទប្បញ្ញត្តិ និងការត្រួតពិនិត្យប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព ។

ជាមួយនេះដែរ រាជរដ្ឋាភិបាលក៏បានអនុម័តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ ឆ្នាំ២០០៦-២០១៥ និង ឆ្នាំ២០១១-២០២០ ដែលក្នុងនោះ ក៏ផ្តោតសំខាន់លើការអភិវឌ្ឍនិងការបង្កើតក្របខ័ណ្ឌច្បាប់ចំពោះវិស័យមីក្រូហិរញ្ញវត្ថុក្នុងការកេណ្ឌប្រមូលនិងបែងចែកធនធាន ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងរួមចំណែកពង្រឹងបរិយាប័ន្នហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយ និងកិច្ចគាំពារអតិថិជន ។

ផ្អែកលើច្បាប់គោលទាំងពីរ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុខាងលើនេះ ធនាគារជាតិនៃកម្ពុជា បានចាប់ផ្តើមពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិ បទបញ្ជាប្រុងប្រយ័ត្ន និងសារាចរណែនាំនានា ដើម្បីប្រែក្លាយអង្គការក្រៅរដ្ឋាភិបាលទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ និងចុះបញ្ជីយោងទៅតាមទំហំប្រតិបត្តិការរបស់អង្គការក្រៅរដ្ឋាភិបាលទាំងនោះ ។ បន្ទាប់ពីទទួលបានអាជ្ញាបណ្ណនិងចុះបញ្ជី គ្រឹះស្ថានទាំងនោះត្រូវស្ថិតក្រោមការត្រួតពិនិត្យជាប់ជាប្រចាំពីធនាគារជាតិនៃកម្ពុជា ។

ក្រៅពីការចេញបទប្បញ្ញត្តិនិងការត្រួតពិនិត្យ ដោយទទួលបានកិច្ចសហការពីដៃគូអភិវឌ្ឍន៍នានា ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុ

កម្ពុជា សន្និសីទតំបន់ស្តីពីមីក្រូហិរញ្ញវត្ថុ និងវេទិកាមីក្រូហិរញ្ញវត្ថុ ជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០៦ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងភាគីពាក់ព័ន្ធផ្សេងទៀត ឱ្យបានជ្រួតជ្រាបអំពីតួនាទី សកម្មភាព ផលប្រយោជន៍ និងការប្រឈមនៃវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ។

ប្រការដែលគួរឱ្យកត់សម្គាល់ក្នុងប្រវត្តិនៃការអភិវឌ្ឍរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជានោះគឺ កាលពីថ្ងៃទី១១-១៣ ខែមករា ឆ្នាំ២០០៦ កន្លងមក ធនាគារជាតិនៃកម្ពុជា សហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានរៀបចំសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការចូលរួមពីសំណាក់ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ម្ចាស់ជំនួយ ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អង្គការក្រៅរដ្ឋាភិបាល និងមជ្ឈដ្ឋានផ្សេងៗទៀត ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានសំដែងការកោតសរសើរចំពោះការវិវត្តន៍នៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា និងបានប្រកាសប្រសិទ្ធនាមជាផ្លូវការនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០៦ ថា "**ឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុកម្ពុជា**" ព្រមទាំងបានដាក់ចេញនូវអនុសាសន៍មួយចំនួន ដើម្បីពង្រឹងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឱ្យមានសុខភាពល្អនិងប្រសិទ្ធភាព ដើម្បីរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ អនុសាសន៍ទាំងនោះរួមមាន ៖

***ទី១ ៖*** ចំពោះធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ត្រូវបន្តការងារសម្អិតសម្អាងនូវបទបញ្ញាប្រុងប្រយ័ត្ន សម្រាប់ត្រួតពិនិត្យឱ្យកាន់តែសុក្រឹតឡើង និងដាក់ឱ្យអនុវត្តឱ្យមានប្រសិទ្ធភាព ដើម្បីការពារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យបានរឹងមាំជាទីទុកចិត្តពីសាធារណជន ។ បទបញ្ញាប្រុងប្រយ័ត្នទាំងនោះ ក៏ត្រូវមានភាពទន់ភ្លន់មិនតឹងតែងពេក ដែលអាចដាក់បន្ទុកទៅលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក៏មិនត្រូវធូរលុងពេក ជាហេតុធ្វើឱ្យមានហានិភ័យខ្ពស់ និយាយរួម គឺបទបញ្ញាទាំងនោះត្រូវគោរពតាមបទដ្ឋានដែលត្រូវប្រើប្រាស់ជាសកល ក្នុងទិសដៅធ្វើឱ្យគ្រឹះស្ថានទាំងនោះធ្វើប្រតិបត្តិការផ្តល់សេវាមាននិរន្តរភាព និងការពារបាននូវផលប្រយោជន៍របស់ប្រជាពលរដ្ឋក្រីក្រ ។

***ទី២ ៖*** ចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលមិនទាន់ទទួលអាជ្ញាបណ្ណ ត្រូវខិតខំពង្រឹងខ្លួនឯង ដើម្បីអាចប្រែក្លាយខ្លួនទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ ដោយធ្វើប្រតិបត្តិការនៅក្រោមច្បាប់ត្រឹមត្រូវ ។

***ទី៣ ៖*** ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណរួចហើយ គប្បីពង្រឹងការគ្រប់គ្រង ពង្រឹងប្រតិបត្តិការរបស់ខ្លួន ដោយបង្កើតឡើងនូវផលិតផលហិរញ្ញវត្ថុថ្មីៗសមស្របជាមួយតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្របន្ថែមទៀត និងពង្រីកបណ្តាញឱ្យកាន់តែទូលំទូលាយចូលជ្រៅដល់ទីជនបទដាច់ស្រយាលនៃប្រទេស ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋក្រីក្រឱ្យកាន់តែច្រើនឡើង ។

***ទី៤ ៖*** ផ្សារភ្ជាប់ជាមួយការផ្តល់សេវាហិរញ្ញវត្ថុនេះ កម្មវិធីបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋដើម្បីឱ្យយល់ដឹងអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ ក៏គួរត្រូវបានយកចិត្តទុកដាក់ផងដែរ ។ ការបណ្តុះបណ្តាលការយល់ដឹងជាមូលដ្ឋាន អាចធ្វើឱ្យប្រជាពលរដ្ឋក្រីក្រយល់ដឹងពីការខ្ចីឥណទាន ការសន្សំប្រាក់ និងការប្រើប្រាស់ប្រាក់ដែលបានខ្ចីឱ្យមានផលប្រយោជន៍ក្នុងការប្រកបរបរចិញ្ចឹមជីវិត បង្កើនប្រាក់ចំណូលដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ។

***ទី៥ ៖*** ចំពោះអត្រាការប្រាក់ឱ្យខ្ចី រាជរដ្ឋាភិបាលនៅតែប្រកាន់យកគោលនយោបាយអត្រាការប្រាក់ទីផ្សារ ក៏ប៉ុន្តែ ទោះបីជាមានការថយចុះអត្រាការប្រាក់ជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមកក្តី ក៏គួរគប្បីភាគីពាក់ព័ន្ធទាំងឡាយក្នុងវិស័យមីក្រូហិរញ្ញវត្ថុជាពិសេស សហគមន៍អន្តរជាតិដែលបានផ្តល់កម្ចីដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកម្ពុជាពិចារណារិះរកមធ្យោបាយយ៉ាងណា ធ្វើឱ្យអត្រាការប្រាក់កាន់តែចុះទាបជាងនេះទៅទៀត ដើម្បីជួយដល់អ្នកខ្ចីក្រីក្ររបស់យើង ។

***ទី៦ ៖*** អនុសាសន៍បន្ថែមចំនួន ៤ ចំនុចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីគឺ (១) រក្សាឱ្យបានស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមឱ្យបានល្អ (២) ត្រូវរក្សាកំណើនសេដ្ឋកិច្ចឱ្យកើនបាន ៦%-៧% (៣) ធ្វើការបែងចែកកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និង (៤) គ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពនិងនិរន្តរភាព ។

ទន្ទឹមនឹងការរីកចម្រើនក្នុងវិស័យមីក្រូហិរញ្ញវត្ថុ រាជរដ្ឋាភិបាលក៏នៅតែបន្តជំរុញការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាពិសេសផ្លូវលំជនបទ ប្រព័ន្ធធារាសាស្ត្រ និងដឹកនាំគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធសមស្រប ដើម្បីធ្វើឱ្យមានស្ថិរភាពប្រាក់រៀល ស្ថិរភាពថ្លៃ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងរក្សាសន្តិសុខសុវត្ថិភាពសង្គមឱ្យកាន់តែប្រសើរឡើង ។ ទន្ទឹមនេះ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវជួយសម្រួលនិងបង្កលក្ខណៈអំណោយផលស្របច្បាប់ ដល់ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការក្នុងដែនដី

នៃរដ្ឋអំណាចរបស់ខ្លួនប្រកបដោយសុវត្ថិភាព ដើម្បីឱ្យប្រតិបត្តិករមីក្រូហិរញ្ញវត្ថុពង្រីកសកម្មភាពឱ្យកាន់តែទូលំទូលាយឡើងគ្របដណ្តប់ទូទាំងប្រទេស ។

យោងតាមអនុសាសន៍ដ៏ថ្លៃថ្លានិងមានអត្ថន័យដ៏ជ្រាលជ្រៅទាំងនេះ ធនាគារជាតិនៃកម្ពុជា ម្ចាស់ជំនួយ និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានឯកភាពគ្នាយកអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដើម្បីពង្រឹងវិស័យមីក្រូហិរញ្ញវត្ថុឱ្យកាន់តែរីកចម្រើនតទៅមុខទៀត ។ អនុវត្តន៍តាមស្មារតីនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំនូវសន្និសីទតំបន់នៅតាមបណ្តាខេត្តមួយចំនួន ដូចជានៅខេត្តបាត់ដំបងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៦ នៅខេត្តកំពតកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦ និងនៅខេត្តកំពង់ចាមកាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៦ ព្រមទាំងបានរៀបចំសិក្ខាសាលានិងវេទិកាថ្នាក់ជាតិនិងថ្នាក់តំបន់ ពាក់ព័ន្ធនឹងប្រធានបទនិងការផ្សព្វផ្សាយស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា បានបន្តរៀបចំកម្មវិធីនិងសិក្ខាសាលាផ្សព្វផ្សាយនានាជូនសាធារណជនឱ្យបានជ្រួតជ្រាបបន្ថែមទៀត អំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា និងការវិវត្តនៃប្រតិបត្តិការរបស់វិស័យមីក្រូហិរញ្ញវត្ថុ ដូចនៅថ្ងៃនេះស្រាប់នាក្រុងសៀមរាប និងបន្តអនុវត្តកម្មវិធីនេះនៅតាមបណ្តាខេត្តផ្សេងៗជាបន្ទាប់ទៀត ។

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយអភិវឌ្ឍសេដ្ឋកិច្ចជនបទតាមរយៈប្រតិបត្តិការស្នូល គឺការផ្តល់ឥណទានដល់ប្រជាជនដើម្បីបង្កើតនិងពង្រីកមុខរបរអាជីវកម្ម ។ ការរីកចម្រើនយ៉ាងទូលំទូលាយនិងពាសពេញផ្ទៃប្រទេសនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា បានធ្វើឱ្យវិស័យនេះទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់វិនិយោគិន ដៃគូអភិវឌ្ឍន៍ អ្នកសិក្សាស្រាវជ្រាវ និងអ្នករៀបចំគោលនយោបាយជាដើម ទាំងនៅក្នុងនិងក្រៅប្រទេស ។ កន្លងមក វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ត្រូវបានទទួលស្គាល់យ៉ាងច្រើននៅលើឆាកអន្តរជាតិ ទាំងលើក្របខណ្ឌបទប្បញ្ញត្តិភាពច្នៃប្រឌិត និងភាពទន់ភ្លន់នៃប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។ ជាឧទាហរណ៍ ក្នុងរបាយការណ៍ដែលចេញផ្សាយដោយអង្គភាពស៊ើបអង្កេតសេដ្ឋកិច្ច ប្រទេសកម្ពុជាបានទទួលចំណាត់ថ្នាក់លេខ១ ក្នុងចំណោមប្រទេសចំនួន ៥៥ លើការដាក់ចេញបទប្បញ្ញត្តិនិងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់ពីរឆ្នាំជាប់គ្នា គឺឆ្នាំ២០០៩ និងឆ្នាំ២០១០ ។ ការទទួលស្គាល់ជាលក្ខណៈអន្តរជាតិបែបនេះ ក៏ត្រូវបានផ្តល់ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាផងដែរ ក្នុងនោះរួមមានការទទួលស្គាល់លើតម្លាភាពហិរញ្ញវត្ថុដែលផ្តល់ដោយស្ថាប័នពិគ្រោះយោបល់សម្រាប់ជួយជនក្រីក្រ (CGAP) និង

ការសម្រេចបានលទ្ធផលផ្នែកសង្គម ដែលផ្តល់ដោយស្ថាប័នដោះដូរព័ត៌មានមីក្រូហិរញ្ញវត្ថុ (MIX Market) ។

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

តាមរយៈការរីកចម្រើននេះ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា បានក្លាយជាចំណុចចាប់អារម្មណ៍របស់អន្តរជាតិ ក្នុងទិសដៅសិក្សាស្វែងយល់ ចែករំលែកបទពិសោធន៍ និងកត្តាជោគជ័យនានាដែលកម្ពុជាទទួលបានកន្លងមក ។ មានប្រទេសមួយចំនួន ក្នុងតំបន់ និងអន្តរជាតិ ក៏បានមករៀនសូត្រនិងបានអញ្ជើញគណៈប្រតិភូពីកម្ពុជា ទៅចែករំលែកបទពិសោធន៍ដែលនាំឱ្យមានជោគជ័យក្នុងការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ។ អ្វីដែលអន្តរជាតិទទួលស្គាល់ជាពិសេស គឺកម្ពុជាអនុវត្តយន្តការទីផ្សារ និងលើកទឹកចិត្តការប្រកួតប្រជែងស្មើភាពគ្នា ដោយមិនកំណត់ពិដានអត្រាការប្រាក់ឡើយ ។

កត្តាពន្លឿនកំណើនវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានគាំទ្រដោយកត្តាសំខាន់ចំនួន ៤ គឺ ទី១- ការកំណត់ចក្ខុវិស័យដ៏វែងឆ្ងាយ និងគោលនយោបាយគាំពារនិងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ ទី២- ក្របខ័ណ្ឌបទប្បញ្ញត្តិនិងការត្រួតពិនិត្យដោយប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ទី៣- ភាពរស់រវើកនិងការច្នៃប្រឌិតរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងទី៤- តម្រូវការនិងការគាំទ្ររបស់អតិថិជន ។

បច្ចុប្បន្ន ប្រជាជនកម្ពុជាមានការយល់ដឹងច្រើនក្នុងការស្វែងរកប្រភពហិរញ្ញប្បទានពីធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយសារមានការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ការបង្កភាពងាយស្រួល និងមានការប្រាក់ទាបជាងអត្រាការប្រាក់កម្ចីរបស់អ្នកឱ្យខ្ចីចងការឯកជនក្រៅផ្លូវការ ។ អតិថិជនមីក្រូហិរញ្ញវត្ថុ ជាពិសេសប្រជាជនដែលរស់នៅតាមតំបន់ជនបទ មិនត្រឹមតែទទួលបានផលប្រយោជន៍តែខ្លួនឯងប៉ុណ្ណោះទេ ថែមទាំងបានផ្តល់ដល់សមាជិកក្រុមគ្រួសាររបស់គាត់ផងដែរ តាមរយៈការបង្កើតឱ្យមានការគាំពារលើម្ហូបអាហារ សុខភាព ការរស់នៅរបស់កូនចៅ និងការចូលរួមក្នុងកម្មវិធីសង្គមនានា ។ លទ្ធភាពនៃការទទួលបានសេវាមីក្រូហិរញ្ញវត្ថុដោយផ្ទាល់របស់ប្រជាពលរដ្ឋក្រីក្រនេះហើយ បានធ្វើឱ្យវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា រក្សាបាននូវតួនាទីដ៏ចាំបាច់របស់ខ្លួនក្នុងការជួយកាត់បន្ថយភាពក្រីក្រ ប៉ុន្តែតួនាទីនេះក៏ត្រូវបញ្ជាក់ឱ្យច្បាស់ផងដែរឬថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពុំមែនធ្វើសកម្មភាពក្នុងរូបភាពជាអង្គការ

មនុស្សធម៌ តាមរយៈការទទួលបានមូលនិធិឥតសំណងពីរាជរដ្ឋាភិបាល ឬម្ចាស់ជំនួយនោះទេ ។ ប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានលក្ខណៈជាអាជីវកម្ម ដែលចាំបាច់ត្រូវស្វែងរកចំណូលក្នុងការទ្រទ្រង់ និងរក្សានិរន្តរភាពប្រតិបត្តិការរបស់ខ្លួន ។ និរន្តរភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ផ្សារភ្ជាប់នឹងនិរន្តរភាពគ្រួសារអតិថិជនផងដែរ ។

### ៣/. ស្ថានភាពទូទៅនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា

ជាមួយនឹងការអនុវត្តតាមគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល និងការអនុវត្តយន្តការទីផ្សារ វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា បានបន្តការរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងទំហំនិងវិសាលភាព ព្រមទាំងការពង្រីកបរិយាប័ន្នហិរញ្ញវត្ថុផងដែរ ។ ជារួម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា បានគោរពយ៉ាងខ្ជាប់ខ្ជួនតាមច្បាប់ជាធរមាន និងបទប្បញ្ញត្តិផ្សេងៗ ដែលធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្ត ដូចជាអភិបាលកិច្ច ការត្រួតពិនិត្យផ្ទៃក្នុង កាតព្វកិច្ចដើមទុន គោលការណ៍កិច្ចការពារអតិថិជន និងបទប្បញ្ញត្តិប្រុងប្រយ័ត្នជាដើម ។

គិតត្រឹមខែធ្នូ ឆ្នាំ២០១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសរុបមានចំនួន ៣៩ ក្នុងនោះគ្រឹះស្ថានចំនួន ៧ ត្រូវបានអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន និងប្រតិបត្តិករឥណទានជនបទដែលចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជាមានចំនួន ៣៨ ។ ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានទឹកប្រាក់សរុប ២ ពាន់លានដុល្លារអាមេរិក ដែលត្រូវបានផ្តល់ដល់អតិថិជន ១,៨០ លាននាក់ ក្នុងនោះស្ត្រីមានចំនួន ៨១% ។ ទន្ទឹមនោះ ប្រាក់បញ្ញើសរុបមានចំនួនប្រមាណ ៩០០ លានដុល្លារអាមេរិក ដែលទទួលបានពីអតិថិជនជាង ១ លាននាក់ ។ បន្ថែមពីនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកំពុងធ្វើប្រតិបត្តិការទូទាំង ២៥ ខេត្ត-ក្រុង ដោយមានបណ្តាញតំបន់ប្រតិបត្តិការនៅថ្នាក់ស្រុកចំនួន ២.៣៣៨ ថ្នាក់ឃុំចំនួន ១៦.១៧៣ និងថ្នាក់ភូមិចំនួន ១០០.៣៤២ ។

ក្រៅពីសេវាឥណទាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក៏មានសេវាមួយចំនួនទៀតដូចជាសេវាប្រាក់សន្សំ សេវាផ្ទេរប្រាក់ សេវាម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ និងសេវាធានារ៉ាប់រងខ្នាតតូចជាដើម ។ សេវាទាំងអស់នេះត្រូវបានផ្តល់ឱ្យអតិថិជន ក្នុងគោលបំណងជួយសម្រួលនិងបង្កើនស្ថានភាពហិរញ្ញវត្ថុគ្រួសារ ក៏ដូចជាអាជីវកម្មរបស់គាត់ឱ្យកាន់តែប្រសើរឡើង ។ បច្ចុប្បន្ន ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង ៣៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៤ បានផ្តល់សេវាកម្មម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិសរុបចំនួន ១៨៩ ម៉ាស៊ីន ក្នុងនោះគ្រឹះស្ថាន ប្រាសាក់មាន ៨១ ម៉ាស៊ីន គ្រឹះស្ថាន

ហត្ថកសិករមាន ៧២ ម៉ាស៊ីន គ្រឹះស្ថានអេអឹមខេមាន ២៥ ម៉ាស៊ីន និងគ្រឹះស្ថានស្ថាបនាមាន ១១ ម៉ាស៊ីន ។

## ៤/. បញ្ហាអត្រាការប្រាក់នៃការផ្តល់ឥណទាន

ករណីអត្រាការប្រាក់ គឺជាបញ្ហាសំខាន់មួយទៀតដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវប្រឈម គឺអត្រាការប្រាក់ឱ្យខ្ចី ។ កន្លងមក អត្រាការប្រាក់ឱ្យខ្ចីក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា គឺជាបញ្ហាមួយត្រូវលើកយកមកពិចារណា ដោយសារអត្រាការប្រាក់នេះមានកម្រិតខ្ពស់ជាងអត្រាការប្រាក់ឱ្យខ្ចីរបស់ធនាគារពាណិជ្ជ ក៏ប៉ុន្តែនៅទាបជាងអត្រាការប្រាក់ក្រៅផ្លូវការ ។ ភាពកង្វល់របស់យើងទាំងអស់គ្នា គឺត្រូវធ្វើយ៉ាងណាដើម្បីឱ្យអត្រាការប្រាក់នោះកាន់តែចុះទាប ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ ។ ប៉ុន្តែតាមបទពិសោធន៍និងការសិក្សាកន្លងមក ការធ្វើឱ្យអត្រាការប្រាក់ចុះទាប មិនមែនជាការដាក់កំហិតពិតានអត្រាការប្រាក់នោះឡើយ ។ ការធ្វើបែបនេះ នឹងនាំឱ្យអ្នកវិនិយោគលើវិស័យនេះមានការរារែក ហើយអាចនឹងមិនវិនិយោគ ឬដកទុនរបស់គេទៅវិញ ដែលជាហេតុធ្វើឱ្យពលរដ្ឋក្រីក្របាត់បង់ឱកាសទទួលសេវាឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ មធ្យោបាយដែលអាចធ្វើឱ្យអត្រាការប្រាក់ចុះទាប គឺការបង្កបរិស្ថានអំណោយផលឱ្យប្រតិបត្តិការហិរញ្ញវត្ថុកាន់តែកុះករឡើង ហ៊ានមកបណ្តាក់ទុនវិនិយោគ ដោយមិនមានការព្រួយបារម្ភអំពីការគៀបសង្កត់ណាមួយ និងពង្រីកដែនប្រតិបត្តិការរបស់គេឱ្យកាន់តែទូលំទូលាយ ។ ដូចនេះ នឹងនាំឱ្យមានការប្រកួតប្រជែងនៅលើទីផ្សាររវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះ ដែលជាហេតុនាំឱ្យអត្រាការប្រាក់ចុះទាប ។

កត្តាកំណត់អត្រាការប្រាក់ឱ្យខ្ចីរួមមាន តម្លៃនៃដើមទុន អតិផរណា សោហ៊ុយចំណាយក្នុងការឱ្យខ្ចី និងប្រាក់ចំណេញសមស្របក្នុងកម្រិតមួយដែលអាចទ្រទ្រង់ឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានដំណើរការដោយនិរន្តរភាព ។ បញ្ហាសំខាន់ គឺធ្វើឱ្យតម្លៃនៃដើមទុនចុះទាប រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកាត់បន្ថយចំណាយ ដូចជា ការបង្កើតឱ្យមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធងាយស្រួលដល់ទីជនបទឆ្ងាយៗជាដើម ។

កត្តាមួយទៀតដែលជះឥទ្ធិពលផងដែរដល់អត្រាការប្រាក់មីក្រូហិរញ្ញវត្ថុ គឺវិធីគណនាអត្រាការប្រាក់ ។ ជាទ្រឹស្តី មានវិធីជាច្រើនដែលត្រូវយកមកប្រើ ដើម្បីគណនាអត្រាការប្រាក់ ហើយលទ្ធផលនៃការគណនាបានបង្ហាញឱ្យឃើញពីអត្រាការប្រាក់ឱ្យខ្ចីពិតប្រាកដប្រចាំឆ្នាំខុសៗគ្នា ។ រហូតដល់បច្ចុប្បន្ន អង្គការក្រៅរដ្ឋាភិបាលដែលធ្វើឱ្យប្រតិបត្តិការវិស័យមីក្រូហិរញ្ញវត្ថុបានប្រកាន់យកវិធីគណនាអត្រាការប្រាក់ខុសៗគ្នា ។

វិធីគណនាខ្លះបានធ្វើឱ្យអ្នកខ្ចីត្រូវខាតបង់លើសពីវិធីគណនាខ្លះទៀត ដូចជាការគណនាអត្រាការប្រាក់លើប្រាក់ដើមដំបូងដែលបានឱ្យខ្ចីដើម្បីសងរំលស់ ជាជាងការគណនាលើសមតុល្យនៃឥណទានជាដើម ហើយជារឿយៗ អ្នកខ្ចីមិនដែលទទួលបាននូវតារាងសម្រាប់សងរំលស់ឥណទានរបស់ខ្លួនឡើយ ។

ដោយស្រាវជ្រាវរកឃើញភាពមិនប្រក្រតីនៃការគណនាអត្រាការប្រាក់នេះ ធនាគារជាតិនៃកម្ពុជា បានចេញជាប្រកាសណែនាំឱ្យប្រតិបត្តិករមីក្រូហិរញ្ញវត្ថុទាំងអស់ប្រកាន់យកនូវវិធីគណនាដែលចេញជាអត្រាការប្រាក់ពិតប្រចាំឆ្នាំទាបបំផុត គឺវិធីនៃការសងរំលស់ និងការគណនាអត្រាការប្រាក់ផ្អែកលើសមតុល្យដែលនៅសល់តែប៉ុណ្ណោះ ។ វិធានការនេះបាននាំឱ្យអ្នកខ្ចីទទួលបាននូវផលចំណេញជាច្រើន ដោយការសងបំណុលទាបជាងពីមុនក្នុងតម្លៃឥណទានដូចគ្នា ។

អត្រាការប្រាក់កម្ចីកំណត់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា មានការថយចុះជាលំដាប់ ។ តាមការសិក្សារបស់ធនាគារជាតិនៃកម្ពុជាបង្ហាញថា អត្រាការប្រាក់ពិតនៃឥណទានប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានថយចុះពី ៣២% ក្នុងឆ្នាំ២០០៩ មកត្រឹម ២៧,៥% ក្នុងឆ្នាំ២០១២ និងរហូតដល់ ២៥% ក្នុងឆ្នាំ២០១៤ ហើយរំពឹងថានឹងបន្តថយចុះជាបន្តបន្ទាប់ទៀត ។ ការថយចុះនេះគឺបណ្តាលមកពីការអនុវត្តយន្តការទីផ្សារ ដែលលើកទឹកចិត្តឱ្យមានការប្រកួតប្រជែងប្រកបដោយតម្លាភាព សំដៅពង្រឹងគុណភាពនៃសេវានិងផលិតផលហិរញ្ញវត្ថុ ។

ទោះបីជាអត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការថយចុះជាបន្តបន្ទាប់ក៏ដោយ ក៏ធនាគារជាតិនៃកម្ពុជានៅមានការបារម្ភពីអត្រាការប្រាក់ខ្ពស់ដែលបណ្តាលឱ្យកូនបំណុលជំពាក់បំណុលរើខ្លួនមិនរួច ហិនហោចទ្រព្យសម្បត្តិ និងចំណាកស្រុក ។ មូលហេតុចម្បងនៃអត្រាការប្រាក់កម្ចីនៅតែមានកម្រិតខ្ពស់នេះ គឺបណ្តាលមកពីសកម្មភាពប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាល សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធ ដែលមិនស្ថិតក្រោមការត្រួតពិនិត្យនិងមិនចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីស្វែងរកប្រាក់ចំណេញ តាមរយៈការធ្វើប្រតិបត្តិការមីក្រូឥណទានជនបទ ។ អង្គការមិនមែនរដ្ឋាភិបាល សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធទាំងនោះ បានចាត់ទុកខ្លួនឯងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្របច្បាប់ និងបានកំណត់យកអត្រាការប្រាក់កម្ចីខ្ពស់ និងការគណនារបៀបសងជារបៀបកេងចំណេញពីប្រជាពលរដ្ឋ ជាមួយនឹងការផ្តល់ភាពងាយស្រួលក្នុងការទទួលបានប្រាក់កម្ចី និងមិនបានវិភាគលទ្ធភាពសងរបស់អតិថិជនឱ្យបានត្រឹមត្រូវ ។

ភាពងាយស្រួលនេះ បានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទទួលបានប្រាក់កម្ចីពីប្រភពច្រើន ហើយជាលទ្ធផល នឹងធ្វើឱ្យពួកគាត់ជាប់បន្ទុកបំណុលវន្តក និងគ្មានលទ្ធភាពសង បំណុលវិញ ហើយទ្រព្យបញ្ចាំរួមមានដីធ្លី ផ្ទះសម្បែង ដីស្រែរបស់ពួកគាត់ត្រូវបាន សមាគម ឈ្មួញ ឬអង្គការស្វែងរកប្រាក់ចំណេញទាំងនោះរឹបអូស ។

ដើម្បីទប់ស្កាត់បញ្ហាដែលបានកើតឡើងនេះ ក៏ដូចជាក្នុងគោលបំណងដើម្បីជួយ ការពារប្រជាពលរដ្ឋ ឱ្យចៀសផុតពីការកេងប្រវ័ញ្ចពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់មិនស្របច្បាប់ទាំងនោះ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុនិងធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីថ្លែងការណ៍រួមមួយ កាលពី ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ដើម្បីបំភ្លឺមតិសាធារណៈជ្រាបថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាបណ្ណពុំមែនជារបស់រដ្ឋទេ ព្រមទាំងថ្កោលទោសចំពោះអង្គការមិនមែន រដ្ឋាភិបាល សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់ទាំងនោះ ឱ្យបញ្ឈប់ជាបន្ទាន់នូវ សកម្មភាពកេងប្រវ័ញ្ចនេះ ។ ក្នុងករណីដែលចង់បន្តសកម្មភាពឱ្យខ្ចីប្រាក់ អង្គការមិន មែនរដ្ឋាភិបាល សមាគម ឬបុគ្គលទាំងនោះ ត្រូវតែធ្វើឡើងក្នុងក្របខណ្ឌច្បាប់ ដោយ ត្រូវចូលខ្លួនមកសុំចុះបញ្ជីឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជា នឹងពិនិត្យគុណវុឌ្ឍិច្បាស់លាស់ ត្រឹមត្រូវ ព្រមទាំងចុះត្រួតពិនិត្យដល់ទីកន្លែងជាមុន ដើម្បីជាមូលដ្ឋានក្នុងការសម្រេចផ្តល់ឬមិនផ្តល់អាជ្ញាបណ្ណ ឬចុះបញ្ជីនៅធនាគារជាតិនៃ កម្ពុជា ។

### ៥/. ធនាគារជាតិនៃកម្ពុជា ជាអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិការលើប្រព័ន្ធធនាគារ

ក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិបច្ចុប្បន្ន បានផ្តល់សិទ្ធិដល់ធនាគារជាតិនៃកម្ពុជា ក្នុងការដោះស្រាយបញ្ហាដូចបានរៀបរាប់ខាងលើ ដោយអាចបញ្ឈប់នូវប្រតិបត្តិការ របស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនមានអាជ្ញាបណ្ណ ឬមិនចុះបញ្ជី ដើម្បីធានាបាននូវ ភាពត្រឹមត្រូវនិងយុត្តិធម៌ចំពោះគ្រឹះស្ថានដែលមានអាជ្ញាបណ្ណនិងចុះបញ្ជី ព្រមទាំង ធានាបាននូវការត្រួតពិនិត្យលើប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង ។

បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលអាជ្ញាបណ្ណត្រូវគោរពតាមច្បាប់ និង បទប្បញ្ញត្តិជាច្រើនរួមមាន ៖ ១- កាតព្វកិច្ចលើដើមទុនអប្បបរមា ២- ការគណនានូវ អនុបាតសន្ទនីយភាព ៣- ការគណនានូវអនុបាតសាធនភាព ៤- ការគណនាអត្រា ការប្រាក់ ៥- ការតម្រូវឱ្យមានការតម្កល់ប្រាក់ធានាលើដើមទុន ៦- កាតព្វកិច្ចស្តីពី អភិបាលកិច្ច ៧- កាតព្វកិច្ចក្នុងការផ្ញើរបាយការណ៍ប្រុងប្រយ័ត្ន របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មឯករាជ្យជាដើម ។ ការតម្រូវមួយចំនួនខាងលើនេះ ក៏ត្រូវបាន

ដាក់ឱ្យប្រតិបត្តិករឥណទានជនបទដែលចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជាអនុវត្តផងដែរ ខណៈដែលគ្រឹះស្ថានមិនមានអាជ្ញាបណ្ណឬមិនចុះបញ្ជីរួចផុតពីកាតព្វកិច្ចទាំងអស់នេះ ។ បន្ថែមពីនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណនិងចុះបញ្ជីត្រឹមត្រូវ ក៏ត្រូវរងនូវការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវអនុវត្តគោលការណ៍សីលធម៌វិជ្ជាជីវៈ ព្រមទាំងត្រូវមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋាភិបាលផងដែរ ។ ដូច្នេះហើយ គ្រឹះស្ថានដែលមានអាជ្ញាបណ្ណទាំងនោះ ក៏ត្រូវរកចំណូលក្នុងកម្រិតសមស្របណាមួយ ដើម្បីរក្សានិរន្តរភាពនៃប្រតិបត្តិការរបស់ខ្លួនផងដែរ ។

## ៦/. ស្ថានភាពអនុវត្តជាក់ស្តែងនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា

ស្ថានភាពអនុវត្តជាក់ស្តែងនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជានាពេលបច្ចុប្បន្នក៏កំពុងប្រឈមនូវបញ្ហាមួយចំនួនដូចខាងក្រោម ៖

- មានមតិមួយចំនួនបានរិះគន់ថា ទោះបីជាវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការអភិវឌ្ឍក្តី ក៏វិស័យនេះពុំមានការអភិវឌ្ឍជាវិជ្ជមានប៉ុន្មានទេ ដោយសារតែវាគ្រាន់តែជាអន្ទាក់ធ្វើឱ្យប្រជាពលរដ្ឋក្រីក្រកាន់តែជំពាក់បំណុលវ័ន្តកបន្ថែមទៀត ។ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា គឺជារបស់ឯកជន ជាគ្រឹះស្ថានស្វែងរកប្រាក់ចំណេញដើម្បីរក្សានិរន្តរភាពប្រតិបត្តិការរបស់ខ្លួន ពោលគឺមិនមែនជាអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការមនុស្សធម៌ដែលផ្តល់ជំនួយដល់អតិថិជនក្រីក្រ ដោយពុំចាំបាច់មានសំណងនោះទេ ។ ដូច្នេះ រាល់សកម្មភាពប្រតិបត្តិការ រួមទាំងការផ្តល់ប្រាក់កម្ចីផង គឺត្រូវផ្តល់ទៅអតិថិជនដែលមានលទ្ធភាពបង្កើតចំណូលនិងសងត្រឡប់វិញ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពុំមែនជាអន្ទាក់ធ្វើឱ្យប្រជាពលរដ្ឋមានបំណុលវ័ន្តកនោះទេ ផ្ទុយទៅវិញ គឺជាជំនួយឱ្យប្រជាពលរដ្ឋនៅតំបន់ជនបទមានលទ្ធភាពទទួលបាននិងប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុស្របច្បាប់ ដែលជាប្រភពដើមទុនសម្រាប់ពង្រីកមុខរបរអាជីវកម្ម និងលើកកម្ពស់កម្រិតជីវភាពរស់នៅ ដើម្បីប្រែក្លាយក្តីស្រមៃរបស់ខ្លួនឱ្យទៅជាការពិតជាក់ស្តែង ។ មានតែសម័យនេះទេ ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានពង្រីកប្រតិបត្តិការរបស់ខ្លួនយ៉ាងទូលំទូលាយទូទាំងផ្ទៃប្រទេស ។ ជាការពិតណាស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនអាចផ្លាស់ប្តូរភាពក្រីក្របានទាំងស្រុងទេ ព្រោះជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្លួនឯង ដែលចង់ប្រែក្លាយខ្លួនឯងឱ្យរួចផុតពីភាពក្រីក្រ តាមរយៈការប្រើប្រាស់ប្រភពទុនទទួលបានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យបានចំទិសដៅ ។ ឧទាហរណ៍ជាក់ស្តែងថា បងប្អូនអាចខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយក

ទៅប្រើប្រាស់ដើម្បីពង្រីកផ្ទៃដីដាំដុះ ឬបង្កើនផលដំណាំដែលនឹងអាចផ្តល់ចំណូលត្រលប់វិញ ហើយយកប្រាក់ចំណូលនេះមួយផ្នែកសងបំណុលត្រលប់ទៅគ្រឹះស្ថានវិញ ហើយមួយផ្នែកទៀតប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ការសិក្សារបស់កូនចៅ ហើយប្រាក់នៅសល់អាចយកទៅសន្សំនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្របច្បាប់ដែលអាចនឹងទទួលបានការប្រាក់បន្ថែមទៀត ។ ការប្រើប្រាស់ប្រាក់កម្ចីត្រឹមត្រូវចំគោលដៅបែបនេះ នឹងជួយធ្វើឱ្យការរស់នៅរបស់បងប្អូនកាន់តែប្រសើរឡើង ហើយអនាគតកូនចៅរបស់បងប្អូនក៏នឹងមានការរីកចម្រើនផងដែរ ។ ផ្ទុយទៅវិញ បើបងប្អូនយកប្រាក់កម្ចីដែលទទួលបាននេះទៅប្រព្រឹត្តល្បែងស៊ីសង ជាការពិតណាស់ នឹងធ្វើឱ្យបងប្អូនមិនអាចរកចំណូលសងបំណុលទៅគ្រឹះស្ថានវិញ ធ្វើឱ្យបងប្អូនគ្មានលទ្ធភាពពង្រីកអាជីវកម្មដែលផ្តល់ប្រាក់ចំណូលមកវិញ និងធ្វើឱ្យបងប្អូនចំណាយពេលវេលាដោយឥតប្រយោជន៍។

- មានការកើនឡើងនូវចំនួនអង្គការក្រៅរដ្ឋាភិបាល សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធដែលធ្វើប្រតិបត្តិការមិនស្របច្បាប់ និងមិនស្ថិតក្រោមការគ្រប់គ្រងនិងចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ។
- មានជនខិលខូចមួយចំនួនបានធ្វើការបោកប្រាស់ប្រជាពលរដ្ឋ តាមរយៈការឃោសនាឱ្យប្រជាពលរដ្ឋយកប្រាក់ទៅដាក់សន្សំជាមួយពួកគេ ដោយសន្យាឱ្យការប្រាក់ខ្ពស់ ដែលនេះគឺជាសកម្មភាពមិនស្របច្បាប់ទាំងស្រុង ។ ដោយរំពឹងថាទទួលបានការប្រាក់ខ្ពស់ ប្រជាពលរដ្ឋមួយចំនួនបានត្បិតត្បៀតការចំណាយសំខាន់ៗប្រចាំថ្ងៃរបស់ខ្លួន ហើយក៏មានប្រជាពលរដ្ឋមួយចំនួនទៀតបានខ្ចីលុយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬពីសាច់ញាតិបងប្អូន ហើយយកទៅសន្សំជាមួយជនខិលខូចទាំងនោះ ។ ទីបំផុត ជនខិលខូចទាំងនោះបានប្រមូលប្រាក់សន្សំនោះរត់បាត់ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋត្រូវទទួលរ៉ាប់រងប្រាក់កម្ចីដែលបានខ្ចីនោះ។
- មានអាជ្ញាធរដែនដីមួយចំនួន កំពុងចូលរួមសហការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងជាមួយគ្រឹះស្ថានស្របច្បាប់និងមិនស្របច្បាប់ តាមរយៈការជួយចេញលិខិតបញ្ជាក់ជូនប្រជាពលរដ្ឋដោយសេរី ឬច្រើនសន្លឹក ដើម្បីប្រើប្រាស់ក្នុងការខ្ចីប្រាក់ និងចូលរួមជួយដើរទារប្រាក់បំណុលពីប្រជាពលរដ្ឋជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ប្រការនេះធ្វើឱ្យមតិសាធារណៈយល់

ច្រឡំថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះជាគ្រឹះស្ថានរបស់រដ្ឋ ដូច្នេះហើយ ខ្ចីប្រាក់គឺពុំបាច់មានកាតព្វកិច្ចសងវិញនោះទេ ។

- មានគណបក្សនយោបាយ និងបុគ្គលមួយចំនួន បាននិងកំពុងកេងយកផលចំណេញផ្នែកនយោបាយ តាមរយៈការដើរឃោសនាឱ្យប្រជាពលរដ្ឋយល់ច្រឡំថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាគ្រឹះស្ថានរបស់រដ្ឋ ដូច្នេះប្រាក់ដែលខ្ចីជារបស់រដ្ឋ ហើយប្រជាពលរដ្ឋខ្ចីប្រាក់មិនចាំបាច់សងប្រាក់កម្ចីនោះត្រលប់វិញទេ ។ ប្រសិនបើពួកគេឈ្នះឆ្នោតនៅអាណត្តិក្រោយ នោះពួកគេនឹងលុបចោលប្រាក់កម្ចីទាំងនោះ ។
- មានបុគ្គលិកឥណទានមួយចំនួនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងស្របច្បាប់ និងមិនស្របច្បាប់ បានឃោសនាលួងលោម ទាក់ទាញ និងបង្ខំឱ្យប្រជាពលរដ្ឋខ្ចីប្រាក់ ដើម្បីបំរើផលប្រយោជន៍ផ្ទាល់ខ្លួន ។

## ៧/. ទិសដៅរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

រួមមក ចក្ខុវិស័យរបស់យើងចំពោះការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ គឺបង្កើតបរិយាប័ន្នហិរញ្ញវត្ថុ (Financial Inclusion) ដោយត្រូវបង្កើតទីផ្សារមីក្រូហិរញ្ញវត្ថុឯកជនដែលអាចដំណើរការបាននិងប្រកបដោយនិរន្តរភាព រួមជាមួយការគាំទ្ររបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌគ្រឹះស្ថានត្រឹមត្រូវសម្រាប់ទីផ្សារនោះ ។ មាគ៌ាឆ្ពោះទៅមុខក្នុងរយៈពេលខ្លីទៅរយៈពេលមធ្យម ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ គឺជាសំណុំយុទ្ធសាស្ត្រចាក់ស្រេះដែលតម្រូវឱ្យយកការចិត្តទុកដាក់ពីអ្នកចូលរួមផ្សេងៗ ។ ទាក់ទិននឹងបញ្ហានេះ បញ្ហាមួយចំនួនគប្បីលើកឡើងសម្រាប់ការអភិវឌ្ឍមីក្រូហិរញ្ញវត្ថុ ៖ បង្កើនលទ្ធភាពប្រើប្រាស់សេវាប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុរបស់ពលរដ្ឋក្រីក្រ បង្កើនភាពសម្បូរបែបរបស់គ្រឹះស្ថាន លើកស្ទួយនិរន្តរភាពហិរញ្ញវត្ថុសម្រាប់មីក្រូហិរញ្ញវត្ថុ ពង្រឹងមីក្រូហិរញ្ញវត្ថុធ្វើអាជីវកម្ម បទបញ្ញា និងការត្រួតពិនិត្យ ។

ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ អត្ថប្រយោជន៍ដែលទទួលបានពីការស្ថិតនៅក្រោមបទបញ្ញាត្រួតពិនិត្យ គឺការពង្រឹងការគ្រប់គ្រងឱ្យបានរឹងមាំ និងគោរពតាមបទបញ្ញាទាំងនោះឱ្យបានត្រឹមត្រូវ នោះគឺគ្រឹះស្ថាននឹងមានដំណើរការល្អ អាចទាក់ទាញបាននូវទំនុកចិត្តពីសាធារណជនមកលើប្រព័ន្ធមីក្រូហិរញ្ញវត្ថុ ។ ការគោរពច្បាប់និងបទបញ្ញាដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជាដោយហ្មត់ចត់ ជាកត្តានាំឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចដំណើរការបានដោយប្រសិទ្ធភាពនិងនិរន្តរភាព ។

ម៉្យាងទៀត ទោះបីជាមានការវិវត្តរីកចម្រើនគួរឱ្យពេញចិត្តយ៉ាងណាក្តី ក៏នេះគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ ដូចនេះ នៅមានការងារជាច្រើនទៀតដែលត្រូវយកចិត្តទុកដាក់បំពេញជាបន្តទៀត ដូចជាការលើកទឹកចិត្តឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពង្រីកបណ្តាញរបស់ខ្លួនទៅទីដាច់ស្រយាល ការខិតខំកេណ្ឌប្រមូលប្រាក់សញ្ញ័យជាដើម ។

លទ្ធផលនិងជោគជ័យដែលទទួលបានមកនេះ មិនអាចកាត់ផ្តាច់ពីការជួយជ្រោមជ្រែងពីសំណាក់អ្នកផ្តល់ជំនួយអន្តរជាតិ ដែលជានិច្ចកាលបានផ្តល់នូវការឧបត្ថម្ភវិស័យមីក្រូហិរញ្ញវត្ថុនេះ ទាំងផ្នែកស្មារតី បច្ចេកទេស និងមូលនិធិ ដើម្បីរួមចំណែកធ្វើឱ្យវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការជឿនលឿន ។

ជាងនេះទៀត គោលនយោបាយដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃរបស់រាជរដ្ឋាភិបាលដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ក៏ជាកត្តាគន្លឹះដែលនាំឱ្យមាននូវជោគជ័យដ៏ធំធេងក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យមីក្រូហិរញ្ញវត្ថុនេះ ដែលជាកត្តាសំខាន់ក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

### ៨/. វិធានការណ៍ដោះស្រាយ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការណ៍ដូចខាងក្រោមនឹងត្រូវបានដាក់ឱ្យអនុវត្ត រួមមាន ៖

***ធនាគារជាតិនៃកម្ពុជា***

- បន្តផ្សព្វផ្សាយសេចក្តីថ្លែងការណ៍រួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ។
- បោះពុម្ពសេចក្តីថ្លែងការណ៍រួមនេះ សម្រាប់ចែកជូនដល់គ្រប់សាខាខេត្ត-ក្រុងរបស់ធនាគារជាតិនៃកម្ពុជា ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ភាគីពាក់ព័ន្ធ និងសាធារណជនទូទៅ ដើម្បីជ្រាបជាព័ត៌មាន ។
- បន្តធ្វើយុទ្ធនាការផ្សព្វផ្សាយជូនដល់សាធារណជនទូទៅ ពិសេស ប្រជាពលរដ្ឋនៅតំបន់ជនបទ ឱ្យបានជ្រួតជ្រាបអំពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា កាតព្វកិច្ចខ្ចីប្រាក់ ចំណេះដឹងមូលដ្ឋានផ្នែកហិរញ្ញវត្ថុ និងការជម្រុញការប្រើប្រាស់ប្រាក់រៀល ជាដើម ។
- បន្តធ្វើយុទ្ធនាការផ្សព្វផ្សាយជូនដល់អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ប្រជាពលរដ្ឋទូទៅ និងភាគីពាក់ព័ន្ធទាំងអស់ ឱ្យយល់ដឹងកាន់តែច្បាស់លាស់អំពីសេវាមីក្រូ

ហិរញ្ញវត្ថុ ការជំពាក់បំណុល និងការទទួលខុសត្រូវរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រមទាំងកាតព្វកិច្ចរបស់អ្នកខ្ចីប្រាក់ និងកិច្ចការពារអតិថិជនជាដើម ។

- បន្តគៀងគរអង្គការមិនមែនរដ្ឋាភិបាល សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធ ដែលធ្វើការឱ្យខ្ចីប្រាក់ដោយពុំទាន់មានច្បាប់អនុញ្ញាត ឱ្យមកស្នើសុំអាជ្ញាបណ្ណឬចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ។
- បន្តសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ សមត្ថកិច្ច និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ដើម្បីបញ្ឈប់សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល សមាគម ឬឈ្មួញឱ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធ ដែលពុំទាន់មានច្បាប់អនុញ្ញាតត្រឹមត្រូវ ។
- ពង្រឹងបន្ថែមលើការអនុវត្តន៍និងការប្រតិបត្តិតាមច្បាប់ បទប្បញ្ញត្តិ និងប្រកាសនានាដែលបានដាក់ឱ្យអនុវត្តកន្លងមក ។
- បន្តបង្កើនប្រសិទ្ធភាពអនុវត្តរបស់ការិយាល័យព័ត៌មានឥណទានកម្ពុជា (Credit Bureau) ដើម្បីជៀសវាងបំណុលជាន់គ្នា និងបំណុលវណ្ឌក ។
- បន្តដាក់ចេញនូវប្រកាសពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន (Consumer Protection) ស្របពេលដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនកំពុងអនុវត្តគម្រោងកម្មវិធីកិច្ចការពារអតិថិជន អនុលោមតាមគោលការណ៍នៃកិច្ចការពារអតិថិជនរបស់ SMART Campaign ។
- ជំរុញការអនុវត្តក្រមស្តីពីការប្រតិបត្តិសេវាធនាគារ (Code of Banking Practice) ដែលទើបតែដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ និងគោលការណ៍កិច្ចការពារអតិថិជន សំដៅការពារផលប្រយោជន៍និងសិទ្ធិរបស់អតិថិជន ។
- បន្តតាមដាននិន្នាការនៃអត្រាការប្រាក់កម្ចី និងលើកទឹកចិត្តឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា បន្តបន្ធូរបន្ថយអត្រាការប្រាក់នេះ ប៉ុន្តែទន្ទឹមនោះ ក៏ត្រូវយកចិត្តទុកដាក់លើការរក្សាប្រាក់ចំណេញរបស់គ្រឹះស្ថានឱ្យប្រកបដោយនិរន្តរភាពផងដែរ ។
- លើកទឹកចិត្តឱ្យសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាសិក្សាអំពីលទ្ធភាពក្នុងការបន្ថយការប្រាក់បន្ថែមទៀត ។

***<u>គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ</u>***

- ត្រូវបន្តជម្រុញនូវការយល់ដឹងរបស់សាធារណជន ពិសេសអតិថិជនរបស់គ្រឹះស្ថាន អំពីផលិតផលនិងសេវាហិរញ្ញវត្ថុ និងចរិកលក្ខណៈរបស់វិស័យទាំងមូល ដើម្បីចៀសវាងការយល់ច្រឡំ ។

- ត្រូវបន្ថែមការអប់រំបណ្តុះបណ្តាលនៅក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ខ្លួន ជាជាងការផ្សព្វផ្សាយពាណិជ្ជកម្មដែលមានលក្ខណៈទាក់ទាញអតិថិជន ដូចជាការផ្សព្វផ្សាយលក់ទំនិញប្រើប្រាស់ ។
- ត្រូវគិតគូរពីគុណភាពជាចម្បង ជាជាងគិតតែពីបរិមាណ ដើម្បីចៀសវាងបំណុលអាក្រក់ដែលមានការកើនឡើង ទោះបីទីផ្សារមានការប្រកួតប្រជែងខ្លាំងយ៉ាងណាក៏ដោយ និងបង្កើនការទទួលខុសត្រូវផ្នែកសង្គម ។
- ត្រូវពង្រឹងបន្ថែមលើការអនុវត្តន៍តាមខ្លឹមសារនៃប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្តីពីការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ លេខធ៧.០១.១១៥ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១ ។
- ត្រូវប្រើប្រាស់ និងបង្ហាញដល់អតិថិជននូវតារាងតម្លាភាពលើការផ្តល់ឥណទានដែលកំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីតម្លាភាពក្នុងការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ លេខធ៧.០១១.២៤៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមចូលរួមមតិមួយចំនួនក៏ដូចជាការស្នើសុំផងដែរ សម្រាប់ជាជំនួយក្នុងការអនុវត្តវិធានការណ៍ខាងលើដូចតទៅ ៖

- អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅតាមបណ្តាខេត្ត ក្រុង ស្រុក ភូមិ ឃុំ ធ្វើការផ្សព្វផ្សាយបន្តនូវខ្លឹមសារនៃសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនប្រជាពលរដ្ឋនៅក្នុងដែនដីរបស់ខ្លួន ។
- អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ គួរបញ្ឈប់ការចេញលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីច្រើនសន្លឹកឬដោយសេរី ជូនប្រជាពលរដ្ឋដើម្បីយកទៅប្រើប្រាស់ក្នុងការខ្ចីប្រាក់ ។
- អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ គួរពិចារណាបញ្ឈប់សកម្មភាពសហការជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទនានា ក្នុងការដើរទារឬប្រមូលប្រាក់កម្ចីពីប្រជាពលរដ្ឋ ដែលនាំឱ្យមានការយល់ច្រឡំថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឬប្រតិបត្តិករឥណទានជនបទទាំងនោះជារបស់រដ្ឋ ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ និងប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ត្រូវកំណត់នូវគោលនយោបាយច្បាស់លាស់ និងដាក់ចេញនូវវិធានការណ៍តឹងរឹង ចំពោះមន្ត្រីនិងបុគ្គលិកគ្រប់រូប ដែលមិនគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន និងក្រមសីលធម៌វិជ្ជាជីវៈ ។

- អង្គការមិនមែនរដ្ឋាភិបាល សមាគម ប្រតិបត្តិករឥណទានជនបទ និងបុគ្គល ដែលធ្វើការឱ្យខ្ចីប្រាក់ ត្រូវតែធ្វើឡើងក្នុងក្របខណ្ឌច្បាប់ គឺត្រូវចូលខ្លួនមកសុំអាជ្ញាបណ្ណ ឬចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ដែលនឹងពិនិត្យគុណវុឌ្ឍិច្បាស់លាស់ត្រឹមត្រូវ មុននឹងផ្តល់ ។ ការរំលងរូសណាមួយដែលផ្ទុយពីការអនុញ្ញាតដោយច្បាប់ នឹងត្រូវទទួលទោសទណ្ឌតាមច្បាប់ជាធរមាន ។

ទន្ទឹមនេះដែរ ខ្ញុំសូមលើកទឹកចិត្តគ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ ឲ្យពង្រីកប្រតិបត្តិការរបស់ខ្លួនជាប្រាក់រៀលបន្ថែមទៀត ដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែទូលំទូលាយ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ការប្រើប្រាស់ប្រាក់រៀលមានសារៈសំខាន់ណាស់ចំពោះសេដ្ឋកិច្ចជាតិនិងសង្គមទាំងមូល ដោយសារការបង្កើនការប្រើប្រាស់ប្រាក់រៀលនឹងរួមចំណែកបង្កើនចំណូលជាតិ រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយលើសពីនេះ ប្រាក់រៀលគឺតំណាងឲ្យអត្តសញ្ញាណជាតិយើងទាំងអស់គ្នា ។ រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា បាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រឹង និងលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល ។ ជាក់ស្តែង ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ តម្រូវការប្រាក់រៀលបានកើនឡើងជាបន្តបន្ទាប់ដែលឆ្លុះបញ្ចាំង តាមរយៈកំណើននៃរូបិយវត្ថុក្នុងចរាចរណ៍ គិតជាមធ្យមប្រមាណ ១៧% និងប្រាក់បញ្ញើជារៀលប្រមាណ ២៤% ។ ទោះជាយ៉ាងណាក៏ដោយ ដុល្លារូបនីយកម្មនៅកម្ពុជាបន្ត ស្ថិតក្នុងកម្រិតខ្ពស់នៅឡើយ ដូចនេះការចូលរួមរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់មានសារៈសំខាន់ណាស់ ដើម្បីបង្កើនការប្រើប្រាស់ប្រាក់រៀលឲ្យបានកាន់តែទូលំទូលាយក្នុងគ្រប់វិស័យ សំដៅបម្រើផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងប្រជាជនយើងទាំងអស់គ្នា ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមជាមួយយើងខ្ញុំ និងកិច្ចសហការខិតខំប្រឹងប្រែងធ្វើឱ្យវិស័យនេះមានការអភិវឌ្ឍជាទីមោទនៈ និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ សូមជួបពុទ្ធពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាផ្សព្វផ្សាយ អំពីសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**!